
តើសេរីភាព
ពិតប្រាកដ ជាអ្វី?
នំម៉ាណាប្រចាំថ្ងៃ


តើសេរីភាព
ពិតប្រាកដ ជាអ្វី?
នំម៉ាណាប្រចាំថ្ងៃ

**តើ** សេរីភាពពិតប្រាកដជាអ្វី? មានពេលមួយ មិត្តភក្តិខ្ញុំម្នាក់បានសួរខ្ញុំ នៅលើបណ្តាញសង្គមថា តើសេរីភាពពិតប្រាកដជាអ្វី? បន្ទាប់ពីបានឮសំណួរនេះ ខ្ញុំក៏បានសម្រេចចិត្តបង្ហោះសារមួយ ក្នុងបណ្តាញសង្គម ដែលមានខ្លឹមសារដូចតទៅ :

*អ្នកប្រហែលជាគិតថា មនុស្សដែលមានសេរីភាពជាងគេ ក្នុងពិភពលោក គឺជាអ្នកដែលអាចធ្វើអ្វីៗតាមចិត្ត នៅពេលណាក៏បាន! អ្នកនោះមិនស្ថិតនៅក្រោមបង្គាប់នរណាម្នាក់ ហើយជាមនុស្សឯករាជ្យ។ អ្នកនោះអាចញ៉ាំអ្វីក៏បាន ហើយអាចនៅតែផ្ទះ មើលទូរទស្សន៍ពេញមួយថ្ងៃក៏បាន។*

*បើដូច្នោះមែន ខ្ញុំពិតជាអាណិតកីឡាករអូឡាំពិកណាស់ ព្រោះពួកគេត្រូវតមនេះ តមនោះ។ ពួកគេមិនត្រូវញ៉ាំអាហារនេះ មិនត្រូវធ្វើការនេះ មិនត្រូវជក់បារី មិនត្រូវផឹកស្រា។ ហើយត្រូវហ្វឹកហាត់រត់ប្រណាំ នៅកន្លែងនេះ នៅកន្លែងនោះ។ ពួកគេត្រូវធ្វើអ្វីៗតាមគោលការណ៍ គ្រឹត្យក្រម និងវិន័យរបស់កីឡាករ គឺមិនអាចធ្វើអ្វីៗតាមចិត្តបាន គឺមិនខុសពីទាសករទេ។ ដូចនេះ ពួកគេមុខជាមានអារម្មណ៍ថា ខ្លួនកំពុងតែជាប់អន្ទាក់ហើយ។*

ខ្ញុំសូមអភ័យទោស បើសិនជាអ្នកគិតថា នេះជាការនិយាយចម្អក ប៉ុន្តែ ខ្ញុំជឿថា អ្នកប្រាកដជាយល់អ្វីដែលខ្ញុំបាននិយាយ។ ខ្ញុំដឹងថា មិត្តភក្តិរបស់ខ្ញុំកំពុងតែបារម្ភថា ការដើរតាមព្រះយេស៊ូវ នឹងនាំឲ្យគាត់បង្ខំចិត្តរស់នៅក្នុងជីវិត ដែលមានពេញទៅដោយបទបញ្ញត្តិហើយ។ ហើយគាត់ចង់មានសេរីភាព។ គាត់គិតថា សេរីភាព គឺជាលទ្ធភាពដែលអាចធ្វើអ្វីបានតាមចិត្ត។ មនុស្សភាគច្រើនប្រហែលជាគិតដូចគាត់ដែរ ប៉ុន្តែ តើនោះជាសេរីភាពពិតប្រាកដឬទេ? ហើយតើសេរីភាពនោះមានភាពខុសប្លែកអ្វីខ្លះ ពីសេរីភាពដែលព្រះយេស៊ូវបានប្រទានយើង?

តើសេរីភាព គឺជាលទ្ធភាពដែលអាចធ្វើអ្វីៗតាមចិត្តឬ?


តើសេរីភាព គឺជាលទ្ធភាព
ដែលអាចធ្វើអ្វីៗតាមចិត្តឬ?

តាមវចនានុក្រម សេរីភាព *“គឺជាលទ្ធភាពដែលអាចនិយាយ គិត ឬធ្វើអ្វីក៏ដោយ ដែលយើងចង់ ដោយមិនស្ថិតក្រោមការគ្រប់គ្រង ឬគ្មានដែនកំណត់”* ។ តើនិយមន័យនេះ ត្រឹមត្រូវឬទេ?

សូមយើងស្រមៃអំពីជីវិតដែលគ្មានបទបញ្ញត្តិ គ្មានច្បាប់ចរាចរណ៍ ច្បាប់ដាក់ទោសអំពើលួចប្លន់ គ្មានអ្វីបង្ខំអ្នកឲ្យទៅសាលារៀន ឬរៀនសូត្រអ្វីមួយទេ គ្មានច្បាប់ប្រឆាំងនឹងឃាតកម្ម ឬសូម្បីតែច្បាប់ប្រឆាំងនឹងមនុស្សដែលរំខានអ្នក ឬតាមពីក្រោយអ្នកពីសាលារៀន ឬពីកន្លែងធ្វើការ រហូតមកដល់ផ្ទះក៏ដោយ។ សូមស្រមៃអំពីជីវិតដែលមានសេរីភាពទាំងស្រុង នៅក្នុងការសម្រេចចិត្ត។ តើអ្នកនឹងមានអារម្មណ៍ថា មានសុវត្ថិភាពឬទេ? តើអ្នកនឹងសប្បាយចិត្តទេ ពេលដែលអ្នកដទៃមានសេរីភាព ក្នុងការធ្វើអ្វីៗតាមចិត្ត *“ដោយមិនស្ថិតក្រោមការគ្រប់គ្រង ឬគ្មានដែនកំណត់”* នោះ? តាមពិត ច្បាប់ដែលយើងមានសព្វថ្ងៃ គឺជាមូលហេតុដែលយើងអាចរស់នៅ ដោយមានសេរីភាព នៅក្នុងសង្គម។

ពេលយើងឮថា យើងអាចធ្វើអ្វីៗតាមចិត្ត ស្តាប់មើលទៅ ដូចជាល្អណាស់ ប៉ុន្តែ សេរីភាពបែបនេះ អាចនាំឲ្យយើងជួបរឿងអាក្រក់ជាច្រើន។ យើងត្រូវការព្រំដែន និងច្បាប់ បើសិនជាយើងចង់រស់នៅ ដោយសុខសាន្ត ក្នុងពិភពលោក ជាមួយមនុស្សជាច្រើន ក្រៅពីខ្លួនយើង។

ប៉ុន្តែ ពេលយើងគិតអំពីសេរីភាព ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងសាលា (ជាឧទាហរណ៍) ប្រហែលមិនមែនជារឿងធំជាងគេ ដែលយើងត្រូវខ្វល់នោះឡើយ។ បញ្ហាចម្បង គឺស្ថិតនៅត្រង់ថា យើងចង់មានឯករាជ្យ ហើយធ្វើការសម្រេចចិត្តដោយខ្លួនឯង។ ដូចនេះ យើងប្រហែលជាគិតថា ព្រះយេស៊ូវហាក់ដូចជាកំពុងតែរារាំងយើង មិនឲ្យមានសេរីភាពនោះ ដោយដាក់ឪពុកម្តាយ ឬគ្រូបង្រៀន ក្នុងជីវិតយើងជាដើម!

ជាការពិតណាស់ បើយើងដើរតាមព្រះអង្គ នោះយើងមិនត្រូវធ្វើអ្វីៗតាមចិត្តយើងទៀតឡើយ។ តើការស្តាប់បង្គាប់ព្រះ នាំឲ្យយើងរស់នៅក្នុងជីវិត ដែលមានពេញទៅដោយបទបញ្ញត្តិ និងភាពធុញទ្រាន់ឬ?


តើព្រះទ្រង់
នឹងធ្វើឲ្យខ្ញុំវេទនាឬ?

កាលនៅវ័យជំទង់ ខ្ញុំមិនហ៊ានទទួលជឿព្រះយេស៊ូវទេ។ ខ្ញុំបារម្ភថា បើខ្ញុំអនុញ្ញាតឲ្យព្រះអង្គគ្រប់គ្រងជីវិតខ្ញុំ នោះព្រះអង្គនឹងធ្វើឲ្យខ្ញុំមានអារម្មណ៍ព្រួយបារម្ភ និងឆ្អែតចិត្តមិនខាន។ ខ្ញុំគិតថា ព្រះអង្គប្រហែលជាចាត់ខ្ញុំឲ្យចេញទៅប្រទេស ដែលមានអាកាសធាតុក្តៅ ហើយមានដីហុយ ហើយនៅទីនោះ ការរស់នៅមានពេញទៅដោយបញ្ហា ឬព្រះអង្គប្រហែលជាប្រាប់ខ្ញុំឲ្យរៀបការជាមួយនរណាម្នាក់ ដែលមានចំណុចល្អ តែគួរឲ្យធុញទ្រាន់។ ដូចនេះ ខ្ញុំសួរខ្លួនឯងថា តើខ្ញុំត្រូវជ្រើសរើសយកព្រះយេស៊ូវ ឬរើសយកសុភមង្គល។

ពេលដែលខ្ញុំសម្រេចចិត្តទទួលជឿព្រះយេស៊ូវ ខ្ញុំក៏បានរកឃើញថា អ្វីៗមិនដូចការគិតរបស់ខ្ញុំទេ។ ខ្ញុំក៏បានរកឃើញសេរីភាព ពេលខ្ញុំដើរតាមព្រះយេស៊ូវ ព្រោះព្រះអង្គបានឲ្យតម្លៃខ្ញុំ និងប្រទានឯកសិទ្ធិដ៏ពិសេស។

ពេលដែលឥស្សរជន ឬអ្នកកាទូតណាម្នាក់មានអភ័យឯកសិទ្ធិ គឺមានន័យថា ពួកគេមានសេរីភាពលើសពីមនុស្សធម្មតា ប៉ុន្តែ សេរីភាពរបស់ពួកគេនៅតែស្ថិតនៅក្រោមអំណាចច្បាប់ដដែល។ ពួកគេមិនអាចច្រាននរណាម្នាក់ទម្លាក់តាមមាត់បង្អួច ឬដុតផ្ទះណាមួយចោលឡើយ។ ពួកគេស្ថិតនៅក្រោមច្បាប់របស់ប្រទេស ដែលពួកគេកំពុងតែស្នាក់នៅ ឬរស់នៅ គឺមានន័យថា ពួកគេមានសិទ្ធិសេរីភាពដែលប្រទេសនោះបានផ្តល់ឲ្យ។ សេរីភាពដែលព្រះយេស៊ូវប្រទានយើង ក៏មានលក្ខណៈស្រដៀងនេះផងដែរ។ ការទទួលជឿព្រះអង្គ គឺមានន័យថា យើងមានឯកសិទ្ធិរស់នៅជាកូនព្រះ យើងមានសិទ្ធិទទួលការការពារ ការដឹកនាំ និងសេចក្តីស្រឡាញ់របស់ព្រះអង្គ។ ប៉ុន្តែ យើងនៅតែត្រូវស្តាប់បង្គាប់ព្រះអង្គ។


សេរីភាព ដែលកើតចេញ
ពីការស្តាប់បង្គាប់

កូនស្រីពៅរបស់ខ្ញុំចេះរត់ នៅអាយុ១៨ខែ។ ពេលនោះ នាងចង់រត់ទៅគ្រប់ទីកន្លែង តែនាងងាយនឹងរត់ចូលផ្លូវថ្នល់។ ដូចនេះ ខ្ញុំក៏បានបង្រៀនកូនតូចម្នាក់នេះ ឲ្យដើរមករកខ្ញុំ ពេលខ្ញុំហៅឈ្មោះនាង។ យើងមានការពិបាកនៅក្នុងការបង្រៀននាង ឲ្យស្តាប់បង្គាប់ ដែលពេលខ្លះ យើងមានការពិបាកខ្លាំង រហូតដល់ថ្នាក់ស្រក់ទឹកភ្នែកទាំងពីរនាក់ តែខ្ញុំបានប្រៀនប្រដៅនាង គឺដើម្បីសុវត្ថិភាពរបស់នាងទេ។ ប៉ុន្តែ មិនយូរប៉ុន្មាន នាងមិនចាំបាច់ត្រូវកាន់ដៃខ្ញុំ នៅគ្រប់ទីកន្លែងទៀតឡើយ។ នាងអាចរត់លេង "ដោយសេរី" ដោយសុវត្ថិភាព ព្រោះនាងចេះស្តាប់សម្លេងខ្ញុំហើយ។

ខ្ញុំធ្លាប់ឮគ្រូអធិប្បាយគ្រីស្ទានម្នាក់ មានប្រសាសន៍ថា "ពេលដែលព្រះគម្ពីរចែងថា "ព្រះជាសេចក្តីស្រឡាញ់" នោះគឺមានន័យថា ព្រះអង្គតែងតែព្យាយាមរារាំងយើង មិនឲ្យប្រព្រឹត្តខុស"។ ហេតុនេះហើយបានជាព្រះទ្រង់ប្រទានយើង នូវព្រះរាជបញ្ញា និងបំរាម។ ព្រះជាម្ចាស់ទតឃើញគ្រោះថ្នាក់ដែលយើងមើលមិនឃើញ ហើយព្រះអង្គជ្រាបថា យើងត្រូវធ្វើដូចម្តេច ដើម្បីឲ្យមានសុវត្ថិភាព គឺមិនខុសពីការដែលខ្ញុំព្យាយាមការពារកូនតូចរបស់ខ្ញុំឲ្យរួចពីគ្រោះថ្នាក់នោះឡើយ។

ព្រះគម្ពីរបានចែងថា ព្រះជាម្ចាស់បានប្រព្រិត្តចំពោះយើង ដូចជាកូនព្រះអង្គ។ តើមានកូនណាដែលឪពុកមិនបានប្រៀនប្រដៅនោះ?(ហេព្រើរ ១២:៧) ហើយ "ព្រះដែលទ្រង់វាយផ្ចាល នោះសំរាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឲ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់ កាលណាយើងត្រូវសេចក្តីផ្ចាញ់ផ្ចាល នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ តែក្រោយមក នោះទើបបង្កើតផលដ៏សុខសាន្ត នៃសេចក្តីសុចរិតដល់អស់អ្នកណាដែលត្រូវរងទ្រាំនោះវិញ"(១២:១០-១១)។ ការអ្វីដែលព្រះអង្គឲ្យយើងធ្វើ និងបញ្ញាប្រឈមដែលព្រះអង្គនាំយើងឆ្លងកាត់ អាចមានការពិបាក នៅពេលខ្លះ។ ប៉ុន្តែ ពេលណាយើងទុកចិត្តព្រះវរបិតាយើង ដោយសូមការដឹកនាំពីព្រះអង្គ នោះព្រះអង្គនឹងជួយនាំផ្លូវយើង ឆ្លងកាត់គ្រោះថ្នាក់ នៃលោកិយនេះ។ យើងនឹងរកឃើញសេរីភាព ដោយដឹងថា ព្រះអង្គដឹកនាំយើង "ដើម្បីប្រយោជន៍យើង"។


សេរីភាព
ពិតប្រាកដ

មានពេលមួយ ព្រះយេស៊ូវមានបន្ទូលអំពីសេរីភាព ទៅកាន់ពួកបណ្តាជន ។ ពួកគេក៏បានឆ្លើយតបថា “យើងរាល់គ្នាជាពូជលោកអ័ប្រាហាំ ក៏មិនដែលធ្វើជាបាវបំរើរបស់អ្នកណាឡើយ ម្តេចក៏អ្នកថា យើងនឹងបានរួចដូច្នេះ?”(យ៉ូហាន ៨:៣៣)។

ប៉ុន្តែ ពួកគេមិនបានដឹងទេថា ពួកគេជាទាសកររបស់ “បាប”(ខ.៣៤)។ ការរស់នៅដោយគ្មានព្រះ គឺមិនមានន័យថា យើងអាចរស់នៅ ដោយមិនមាននរណាម្នាក់ហាមឃាត់យើងនោះឡើយ។ បើព្រះជាម្ចាស់មិនបានគ្រប់គ្រងជីវិតយើងទេ នោះអំពើបាបនឹងគ្រប់គ្រងយើងមិនខាន។ ហើយអំពើបាបមិនដែលគិតពីប្រយោជន៍យើងឡើយ(រ៉ូម ៦:១៦-២៣)។ បាបគឺជាភាពអាត្មានិយមរបស់យើង ដែលធ្វើឲ្យយើងចង់ធ្វើអ្វីៗតាមចិត្ត ដោយមិនខ្វល់អំពីព្រះ ឬផ្លូវរបស់ព្រះអង្គឡើយ។ វាធ្វើឲ្យយើងដេញតាមសុភមង្គល ហើយបន្តធ្វើអ្វីៗហួសដែនកំណត់ ដើម្បីបំពេញសេចក្តីប៉ងប្រាថ្នារបស់យើង ដែលនាំឲ្យយើងទទួលការជំនុំជម្រះពីព្រះជាម្ចាស់ បន្ទាប់ពីយើងស្លាប់ទៅ(រ៉ូម ៥:១២ និង ហេព្រើរ ៩:២៧)។

ថ្មីៗនេះ ខ្ញុំបានជួបអ្នកញៀនស្រាម្នាក់ ឈ្មោះប្រែ្វង(Frank)។ ដើម្បីឲ្យខ្លួនគាត់អាចដេកលក់ ជារៀងរាល់យប់ គាត់បានផឹកស្រាវ៉តកាអស់មួយដប។ បន្ទាប់ពីគាត់ក្រោកពីដំណេក គាត់ក៏បានផឹកស្រាវ៉តកាទៀត។ គាត់មិនព្រមចុះចូលព្រះ ឬ នរណាម្នាក់ឡើយ គឺចុះចូលស្រាតែមួយមុខប៉ុណ្ណោះ។ នោះហើយជាបញ្ហារបស់លោកប្រែ្វង។ គាត់មិនបានគ្រប់គ្រងជីវិតខ្លួនឯងទេ តែស្រាបានកាន់កាប់ជីវិតគាត់។ ប៉ុន្តែ គាត់បានជាប់អន្ទាក់វាខ្លាំងពេក បានជាគាត់មិនអាចមើលដឹងថា វាកំពុងតែគ្រប់គ្រងជីវិតគាត់។ ក្រោយមក នៅយប់មួយ លោកប្រែ្វងក៏បានសម្រេចចិត្តឈប់ឲ្យស្រាគ្រប់គ្រងជីវិតគាត់ទៀត។ នៅយប់នោះ ខ្ញុំបានឮគាត់អធិស្ឋានទៅកាន់ព្រះយេស៊ូវថា គាត់ឈប់ដើរតាមផ្លូវរបស់គាត់ទៀតហើយ ហើយចាប់តាំងពីពេលនោះមកគាត់សូមឲ្យព្រះអង្គដឹកនាំជីវិតគាត់វិញ។ សព្វថ្ងៃនេះ គាត់មិនល្អឥតខ្ចោះទេ (គាត់នៅតែត្រូវការការលើកទឹកចិត្ត និងបានទៅទទួលការព្យាបាល) ប៉ុន្តែ គាត់បានក្លាយជាមនុស្សថ្មីហើយ។ ព្រះយេស៊ូវបានរំដោះគាត់ឲ្យមានសេរីភាព។ គាត់បានស្គាល់សេរីភាពពិតប្រាកដ ពេលដែលគាត់បានដឹងថា ព្រះអង្គស្រឡាញ់គាត់ ដូចជាកូនព្រះអង្គ និងកំពុងតែកែប្រែអាកប្បកិរិយារបស់គាត់ ហើយកំពុងតែរៀនចំកន្លែងមួយ សម្រាប់គាត់នៅ




នគរស្ថានសួគ៌(យ៉ូហាន ១៤:១-៣)។

សេរីភាពដែលព្រះយេស៊ូវបានប្រទាន គឺសម្រាប់មនុស្សគ្រប់គ្នា។ សូមយើងស្វែងយល់អំពីអត្ថន័យពិតប្រាកដនៃសេរីភាព ដូចតទៅ :

*សេរីភាពរួចពីទោសកំហុស* : គឺមានន័យថាយើងត្រូវឈប់មានអារម្មណ៍ប្រកាន់ទោសខ្លួនឯង។ ប៉ុន្តែ ពេលណាយើងមានអារម្មណ៍ប្រកាន់ទោសខ្លួនឯង យើងអាចនឹកចាំថា ព្រះយេស៊ូវបានរំដោះយើងឲ្យរួចពីទោសនៃអំពើបាបរបស់យើង ដើម្បីជាប្រយោជន៍យើង (ហេព្រើរ ៩:២៦)។ ព្រះអង្គបានសន្យាយើងថា : “ឯទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណា ទ្រង់បានដកយកអស់ទាំងការល្មើសនៃយើង ឲ្យឃ្លាតឆ្ងាយពីយើងយ៉ាងនោះដែរ” (ទំនុកដំកើង ១០៣:១២)។

ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ដើម្បីបង់ថ្លៃលោះយើង ឲ្យរួចពីទោសកំហុសនៃអំពើបាបគ្រប់យ៉ាង គឺអំពើបាបដែលធ្វើឲ្យយើងមានក្ដីអាម៉ាស់ អំពើបាបដែលយើងសង្ឃឹមថា គ្មាននរណាម្នាក់ដឹង។ ការប្រោសលោះរបស់ព្រះអង្គ បានលាងសម្អាតយើង ឲ្យជ្រះស្អាតទាំងស្រុង នៅចំពោះព្រះ។ យើងមានសេរីភាពរួចពីក្រឹត្យវិន័យ និងទោសនៃអំពើបាប។ ព្រះអង្គបានបង់ថ្លៃលោះអំពើបាបរបស់យើង គឺរាប់បញ្ចូលទាំងអំពើបាបដែលយើងមិនទាន់បានប្រព្រឹត្តផងដែរ។

*សេរីភាពរួចពីការព្រួយបារម្ភ* : អ្វីៗគ្រប់យ៉ាងរបស់យើង គឺនៅក្នុងព្រះហស្តដ៏មានអំណាច និងពេញដោយក្តីស្រឡាញ់របស់ព្រះយេស៊ូវ ដែលរាប់បញ្ចូលទាំងអនាគត និងសេចក្តីស្លាប់របស់យើងផងដែរ។ ផ្ទះរបស់ព្រះអង្គ បានក្លាយជាផ្ទះយើង ហើយព្រះអង្គបានសន្យាថា នឹងដឹកនាំយើង ទៅដល់នគរស្ថានសួគ៌ដោយសុវត្ថិភាព។ ហើយព្រះអង្គក៏បានសន្យាថា នឹងគង់នៅជាមួយយើងគ្រប់ជំហាន ក្នុងការធ្វើដំណើរនេះ។ គ្មានអ្វីក្នុងលោកនេះ ដែលអាចពង្រាត់យើងចេញពីសេចក្តីស្រឡាញ់របស់ព្រះអង្គបានឡើយ(រ៉ូម ៨:៣៨-៣៩)។ ពេលណាយើងមានការភ័យខ្លាច យើងអាចនឹកចាំថា “ព្រះអង្គគង់នៅជាមួយខ្ញុំជានិច្ច។ ខ្ញុំនឹងមិនខ្លាចអ្វីឡើយ”(ទំនុកដំកើង ១១៨:៦)។

*សេរីភាពរួចផុតពីវិប្បដិសារី* : ឱកាសដែលកន្លងផុតទៅ (និងឱកាសទាំងអស់ដែលត្រូវមកទៀត) មិនមែនជាកត្តាកំណត់ថា យើងជានរណាទៀតឡើយ។ ព្រះយេស៊ូវកំពុងដឹកនាំយើង ដូចនេះ យើងមិនចាំបាច់ត្រូវតប់ប្រមល់ ដោយសារឱកាសដែលកន្លងផុតទៅនោះឡើយ។ ព្រះអង្គនឹងដឹកនាំយើង និងជួយឲ្យយើងលូតលាស់ តាមផ្លូវដ៏ត្រឹមត្រូវ។ ព្រះអង្គជ្រាបអំពីផែនការដ៏ឥតខ្ចោះ ដែលព្រះអង្គមានសម្រាប់យើង។ ការនេះមិនមានន័យថា យើងនឹងមិនមានការស្តាយក្រោយទៀតនោះឡើយ យើងនឹងជួបរឿងជាច្រើនទៀត ដែលធ្វើឲ្យយើងស្តាយក្រោយ។ ប៉ុន្តែ ពេលណាយើងស្តាយក្រោយ ព្រះគម្ពីរប្រាប់យើងថា យើងអាចនាំទុក្ខព្រួយរបស់យើងថ្វាយដល់ព្រះ ហើយសម្រាកក្នុងការកម្សាន្តចិត្ត និងការអត់ទោសរបស់ព្រះអង្គ។ ព្រះអង្គប្រទានយើងនូវសេរីភាពរួចផុតពីវិប្បដិសារីហើយ គឺមិនសព្វព្រះទ័យឲ្យយើងនៅជាប់ខ្លួននៅក្នុងការស្តាយក្រោយទៀតឡើយ(២កូរិនថូស ៧:៩-១០)។

*សេរីភាព ដើម្បីស្រឡាញ់* : សាវ័កប៉ុលបានប្រាប់យើងថា “បងប្អូនអើយ ព្រះទ្រង់បានហៅអ្នករាល់គ្នាមក ឲ្យមានសេរីភាព តែកុំឲ្យប្រើសេរីនោះ ទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបំរើគ្នាទៅវិញទៅមកដោយសេចក្តីស្រឡាញ់វិញ”(កាឡាទី ៥:១៣)។

ពេលណាយើងមានសេរីភាពរួចផុតពីអំពើបាប គឺមានន័យថា យើងអាចរៀនស្រឡាញ់ និងបម្រើអ្នក

ដទៃ ដូចដែលព្រះយេស៊ូវបានធ្វើសម្រាប់យើង កាលព្រះអង្គគង់នៅលើផែនដី។ គឺរាប់បញ្ចូលអ្នកដែលយើងមិនចង់នៅក្បែរផងដែរ។ ដោយសារការយល់ដឹងរបស់យើងមានកំណត់(ច្រើនតែមានចំណុចខ្វះខាត) ជាញឹកញាប់ យើងជៀសវាងក្មេងដែលមានលក្ខណៈចម្លែកខុសគេ នៅសាលារៀន និងអ្នកដែលមានលក្ខណៈខុសពីយើងជាដើម។ ប៉ុន្តែ ដោយសារព្រះវិញ្ញាណរបស់ព្រះបានបង្រៀនយើង ឲ្យស្គាល់សេចក្តីស្រឡាញ់ ដែលព្រះយេស៊ូវមានចំពោះមនុស្សគ្រប់គ្នា ដែលព្រះអង្គបានបង្កើត នោះយើងអាចសម្រេចចិត្តរាប់អាន និងបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សគ្រប់គ្នា ដោយមិនរើសមុខ(អេភេសូរ ៥:១៨)។

*សេរីភាព សម្រាប់ផ្លាស់ប្រែឲ្យបានល្អបំផុត តាមដែលអាចធ្វើទៅបាន* : *"តើខ្ញុំជានរណា?" "តើមានរឿងអ្វីកើតឡើង ពេលដែលខ្ញុំប្រឡងធ្លាក់?" "តើខ្ញុំនឹងធ្វើការងារអ្វី ពេលដែលខ្ញុំរៀនចប់?"* ទាំងនេះសុទ្ធតែជាសំណួរសំខាន់ៗ តែយើងមិនចាំបាច់ត្រូវមានចិត្តតប់ប្រមល់ ឬព្រួយបារម្ភដោយសារពួកវាឡើយ។ ព្រះជាម្ចាស់បានបង្កើតយើងមក ហើយជ្រាបច្បាស់ថា យើងចូលចិត្តធ្វើអ្វី ហើយតើអ្វីដែលយើងសមនឹងទទួល ឬសក្តិសមនឹងយើង។ យើងអាចទុកចិត្តលើផែនការ ដែលព្រះអង្គមានសម្រាប់ជីវិតយើង។ យើងមានសេរីភាព ក្នុងការសម្រាក និងទុកចិត្តការដឹកនាំរបស់ព្រះយេស៊ូវ។

ឧបមាថា មិត្តភក្តិរបស់អ្នកម្នាក់បានទិញទូរស័ព្ទទំនើបទាន់សម័យបំផុត ហើយបន្ទាប់មក គាត់បានយកវាទៅកល់ជើងតុកុំឲ្យបាស់បើក។ អ្នកក៏បានសួរគាត់ថា ហេតុអ្វីគាត់ខ្ជះខ្ជាយលុយយ៉ាងនេះ។ គាត់ប្រហែលជានិយាយថា *"វាមានកម្រាស់ល្មមនឹងអាចកល់តុឲ្យបាននឹងល្អ"* ។ គេប្រហែលជាអាចប្រើវាដើម្បីកល់ជើងតុមែន។ ប៉ុន្តែ គេមិនបានរចនា និងផលិតទូរស័ព្ទនោះមក សម្រាប់កល់ជើងតុឡើយ។ គេអាចប្រើវា ដើម្បីកល់ជើងតុបាននឹងល្អ ប៉ុន្តែ វាមានប្រយោជន៍ជាង បើសិនជាគេប្រើវា ជាទូរស័ព្ទទំនើប។ អ្នកប្រហែលជាអាចធ្វើការអ្វីមួយបានល្អ ប៉ុន្តែ តើអ្នកដឹងថា ព្រះបានរចនាអ្នកមក សម្រាប់ឲ្យធ្វើកិច្ចការនោះឬ? មានតែព្រះជាម្ចាស់ទេ ដែលជ្រាបច្បាស់ថា ព្រះអង្គបានបង្កើតអ្នកមកឲ្យធ្វើអ្វី។ ដូចនេះ មានតែថ្វាយជីវិតអ្នកក្នុងព្រះហស្តព្រះអង្គប៉ុណ្ណោះ ទើបអ្នកអាចរស់នៅត្រូវតាមបំណងព្រះទ័យព្រះអង្គ។


អ្វីដែលទូលបង្គំចង់បានក្នុងជីវិតនេះ
គឺចង់ធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គ។

ថ្មីៗនេះ ខ្ញុំបានស្ដាប់រឿង ដែលនិយាយអំពីការដេញថ្លៃទាសករ នៅទសវត្សរ៍ឆ្នាំ១៨៥០ គឺនៅសម័យ ដែលការជួញដូរទាសករដ៏សាហាវព្រៃផ្សៃ នៅបន្តមាន។ មានបុរសម្នាក់បានដើរកាត់ផ្សារមួយ ហើយក៏បានឃើញពួកអ្នកមានមួយចំនួន កំពុងតែដេញថ្លៃទិញនារីដ៏ស្រស់ស្អាតម្នាក់។ ពួកគេសម្លឹងមើលនាងមិនដាក់ភ្នែក ដោយចិត្តអាក្រក់គ្មានមនុស្សធម៌ ខណៈពេលដែលការដេញថ្លៃរបស់ពួកគេ បានឡើងថ្លៃកាន់តែខ្ពស់ឡើងៗ លើសពីតម្លៃខ្លួនធម្មតារបស់ទាសករនៅសម័យនោះ។ បុរសម្នាក់នោះមិនអាចឈរមើលទៀតបាន។ ពេលគាត់បានឮពួកគេជជែកគ្នា អំពីទង្វើអាក្រក់ជួរជាតិដែលពួកគេអាចប្រព្រឹត្តមកលើនារីវ័យក្មេងដ៏កំសត់នោះ គាត់ក៏ទប់ចិត្តលែងបាន។ ដូចនេះ គាត់ក៏បានដេញថ្លៃទិញនាង។ មុននោះ ការដេញថ្លៃបានឡើងដល់តម្លៃដ៏ខ្ពស់ខុសពីធម្មតា តែពេលនេះ គាត់បានដេញថ្លៃលើសនោះទ្វេរដង។ ការដេញថ្លៃក៏បានបញ្ចប់ជាស្ថាពរ ហើយគេក៏បានប្រគល់នាងទៅគាត់ តែកែវភ្នែករបស់នាងមានពេញដោយសេចក្ដីសម្អប់ចំពោះគាត់។

គាត់ក៏បាននាំនាងឆ្លងថ្នល់ ចូលទៅក្នុងការិយាល័យរបស់មេធាវីតែម្ដង។ បន្ទាប់ពីការសន្ទនាបានពីរបីម៉ាត់ បុរសនោះក៏បានងាកទៅរកនារីនោះ ដោយប្រគល់ឯកសារមួយចំនួនដល់នាង។ គាត់ប្រាប់នាងថា *“នេះជាឯកសារដែលបញ្ជាក់ថា នាងមិនមែនជាទាសករទៀតទេ។ នាងមានសេរីភាពហើយ”*។

សេចក្ដីសម្អប់នៅលើមុខនាង ក៏បានជំនួសដោយភាពភ្ញាក់ផ្អើល។ នាងសួរគាត់ថា “លោកទិញខ្ញុំ ដើម្បីរំដោះខ្ញុំឲ្យមានសេរីភាពឬ?”

គាត់ក៏បានឆ្លើយថា “បាទ នាងមានសេរីភាពហើយ”។

ក្មេងស្រីម្នាក់នោះក៏បានក្រាប នៅលើកម្រាលឥដ្ឋ ទួញយំនៅទៀបជើងគាត់ រួចនិយាយទាំងខ្សឹបខ្សួលថា *“លោកបានទិញខ្ញុំ ដើម្បីរំដោះខ្ញុំឲ្យមានសេរីភាព! ពេលនេះ អ្វីដែលខ្ញុំចង់បានក្នុងជីវិត*

*នេះ គឺចង់ធ្វើជាកម្មសិទ្ធិរបស់លោក”។*

ព្រះយេស៊ូវបានទិញយើង និងរំដោះយើងឲ្យមានសេរីភាព តាមរបៀបស្រដៀងនេះផងដែរ។ ព្រះអង្គបាននាំយើងចេញពីក្រឹត្យក្រមនៃអំពើបាប ដើម្បីឲ្យយើងបានធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គវិញ (កូល៉ុស ១:១២-១៤ )។ យើងមិនមែនជាទាសករនៃអំពើបាប ដែលទូលទុក្ខ និងអស់សង្ឃឹមទៀតឡើយ។ ឥឡូវនេះ យើងជាកូនរបស់ព្រះ!

ការមានសេរីភាពពិតប្រាកដ គឺមិនមានន័យថា យើងមិនមាននរណាម្នាក់មើលការខុសត្រូវមកលើយើងនោះទេ។ សេរីភាពពិតប្រាកដ គឺជាការធ្វើជាកម្មសិទ្ធិរបស់ព្រះមួយអង្គ ដែលស្រឡាញ់យើងយ៉ាងជ្រាលជ្រៅ ហើយគិតពីប្រយោជន៍យើងជានិច្ច។ ការនេះគឺមិនខុសពីរឿងរបស់ក្មេងស្រីដែលជាទាសករ ដែលគេបានលោះនោះឡើយ។ ពេលណាយើងបានដឹងថា ព្រះដែលបានលោះយើង ទ្រង់ល្អ និងមានក្តីស្រឡាញ់ច្រើនប៉ុណ្ណោះចំពោះយើង នោះយើងនឹងបានដឹងថា ទ្រង់ក៏នឹងមិនធ្វើបាបយើង ធ្វើឲ្យយើងឈឺចាប់ បំបិទសិទ្ធិយើង ធ្វើឲ្យយើងអាម៉ាស់ ឬចាប់ចងយើងនោះឡើយ។ ចូរយើងប្រើសេរីភាពដែលព្រះយេស៊ូវបានប្រទាន ដើម្បីឲ្យយើងបានរួចពីបាប និងសេចក្តីស្លាប់ខាងវិញ្ញាណ ដើម្បីរស់នៅថ្វាយព្រះអង្គ ដោយការអរព្រះគុណ ហើយបង្ហាញឲ្យគេស្គាល់សេរីភាពពិតប្រាកដ តាមរយៈទីបន្ទាល់នៃការរស់នៅរបស់យើង។

បើសិនជាលោកអ្នកចង់ស្វែងយល់បន្ថែម អំពីព្រះយេស៊ូវ សូមចូលទៅកាន់វេបសាយរបស់នំម៉ាណាប្រចាំថ្ងៃ តាមអាស័យដ្ឋាន https://khmer-odb.org យើងខ្ញុំរង់ចាំបម្រើលោកអ្នកជានិច្ច។ វេបសាយរបស់យើងខ្ញុំ មានកូនសៀវភៅជាច្រើន ដែលអាចទាញយក ឬ download ដោយឥតគិតថ្លៃ ដើម្បីស្វែងយល់បន្ថែមអំពីព្រះអង្គ ភស្តុតាងនៃព្រះវត្តមានរបស់ព្រះអង្គ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។

ប្រភពដ៏ល្អបំផុត សម្រាប់ស្វែងយល់អំពីព្រះយេស៊ូវ គឺព្រះគម្ពីរប៊ីប។ សូមស្វែងរកព្រះគម្ពីរប៊ីប ហើយចាប់ផ្តើមអានកណ្ឌគម្ពីរ "យ៉ូហាន"។ បទគម្ពីរនេះពិពណ៌នា អំពីព្រះជន្មគង់នៅ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។

"បងប្អូនអើយ ព្រះទ្រង់បានហៅអ្នករាល់គ្នាមក ឲ្យមានសេរីភាព តែកុំឲ្យប្រើសេរីនោះ ទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបំរើគ្នាទៅវិញទៅមក ដោយសេចក្តីស្រឡាញ់វិញ"។ កាឡាទី ៥:១៣

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: ® 2018 ODB Ministries (website: www.odb.org)